មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តពោធិ៍សាត់

# សារធាតុចិញ្ចឹមសម្រាប់ដំណាំស្រូវ






រៀបរៀងដោយ លោកស្រី យឹម សុភី

អនុប្រធាន ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម


ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៧


Email: ysophy168@gmail.com and 012 558 312

# និយមន័យអំពីជី

ជាសារធាតុដែលត្រូវបន្ថែមទៅអោយដីដើម្បីបំពេញគុណភាពដែលបាត់បង់ ជាពិសេសតាមការស្រូបយករបស់រុក្ខជាតិ។

# ប្រភេទដី

- មានដីពីរប្រភេទ
  - ដីសរីរាង្គ ឬ ដីធម្មជាតិ
  - ដីអសរីរាង្គ ឬដីគីមី

យើងនឹងលើកយកប្រភេទដីទាំងពីរនេះមកធ្វើការពិភាក្សា ប៉ុន្តែយើងនឹងពិភាក្សាលម្អិតពីដីអសរីរាង្គ (ដីគីមី)។

# ជីសរីរាង្គ

– ***ជីសរីរាង្គ***: *គឺជាប្រភេទជីដែលផលិតចេញពីសារធាតុសរីរាង្គ មានដូចជា៖ លាមកសត្វ កាកសំណល់រុក្ខជាតិ និងសារធាតុខនិជពុកផុយៗ ដូចជាជីកំប៉ុស ។ ជីសរីរាង្គទាំងនេះមានកម្រិតសារធាតុ*





# ជីសរីរាង្គ

ចិញ្ចឹមទាប ហើយជួនកាលនៅពេលយើងប្រើប្រាស់វា យើងមិនបានដឹងអំពីភាគរយនៃសារធាតុចិញ្ចឹមរបស់ដីទាំងនោះ ហេតុដូច្នេះហើយទើបយើងមានការលំបាកបំផុតក្នុងការប្រើប្រាស់ដីឲ្យបានត្រឹមត្រូវទៅតាមតម្រូវការសារធាតុចិញ្ចឹមពិតប្រាកដរបស់រុក្ខជាតិ។

# ជីអសរីរាង្គ

**ជីអសរីរាង្គ ឬជីគីមីៈ** គឺជាប្រភេទជីដែលផលិតចេញពីរោងចក្រ មានទម្រង់ជាគ្រាប់ ជាទឹក ឬជាម្សៅ ជាទូទៅប្រភេទជីទាំងនោះមានផ្ទុកបរិមាណសារធាតុចិញ្ចឹមយ៉ាងច្រើនដែលរុក្ខជាតិត្រូវការ ហើយគេអាចប្រើប្រាស់






# ជីអសរីរាង្គ

ដោយផ្ទាល់ ឬលាយបញ្ចូលគ្នា(ជាទម្រង់សមាស) ក្នុងពេលតែមួយ ដើម្បីផ្តល់ជាជម្រើសដល់កសិករក្នុងការប្រើប្រាស់ដោយផ្អែកលើតម្រូវការដាក់ស្នែងរបស់រុក្ខជាតិ។

# ជីអសរីរាង្គ

- ជីទោល
  - ជីអ៊ុយរ៉េ (N 46%)
  - ជីប៉ូតាស្យូមក្លរួឬជីកាលី ($K_2O$ 60%)
- ជីសមាស
  - ជីដេអាប៉េ 18-46-0 (N 18%, P 46%)
  - ជី 16-20-0 (N 16%, P 20%)
  - ជី 15-15-15 (N 15%, P 15%, K 15%)

# ជីអសរីរាង្គ


46.0.0
NITROGEN
BIURET
MOISTURE


D.A.P
18-46-0
C.S.A
NOLOGY OF U.S.A
PRODUCT OF P.R.C
USE NO HOOKS
DAP 18-46-0


ISO 9001
KALI
(MOP)
CANPOTEX LIMITED
NEWQUEST (TRADING) PTE LTD
CANADA
$K_2O \geq 60\%$

# ជីអសរីរាង្គ










ទទួលបានទិន្នផលខ្ពស់

# ដី

នៅក្នុងដីគួរតែមានគ្រប់នូវសារធាតុចិញ្ចឹមទាំងអស់ បើមិនដូច្នោះទេយើងត្រូវប្រើប្រាស់ដីរបន្ថែម។ អាស្រ័យហេតុនេះហើយសំខាន់បំផុតយើងត្រូវមានការយល់ដឹងអំពីសមាសធាតុគីមីរបស់ដីដែលយើងប្រើប្រាស់សម្រាប់ដាំដុះដំណាំ។

# ដី

រុក្ខជាតិស្រូបយកសារធាតុចិញ្ចឹមក្នុងទម្រង់ជាសូលុយស្យុងតាមរយៈឫស។ រុក្ខជាតិមានការលំបាកក្នុងការស្រូបយកសារធាតុចិញ្ចឹមតាមរយៈស្លឹក (ដីទឹក)។ តម្រូវការបរិមាណសារធាតុចិញ្ចឹមរបស់រុក្ខជាតិផ្អែកទៅតាមវដ្តជីវិតរបស់ដំណាំ ហេតុនេះហើយការប្រើប្រាស់ដីត្រូវយល់ដឹងអំពីដំណាក់កាលនិងពេលវេលាដែលដំណាំត្រូវការសារធាតុចិញ្ចឹម។

# តួនាទីរបស់សារធាតុចិញ្ចឹម

- អាសូត (N)

- តួនាទីរបស់អាសូត (N)
- ជំរុញការដុះលូតលាស់រហ័ស
- បង្កើនទំហំស្លឹក ទំហំគ្រាប់ ចំនួនគ្រាប់ ភាគរយគ្រាប់ពេញ និងបរិមាណប្រូតេអ៊ីនក្នុងគ្រាប់។

- កង្វះអាសូត(N)
- ស្លឹកមានពណ៌បៃតងស្រាល
- ស្លឹកចាស់ប្រែជាពណ៌លឿង និងចាប់ខ្លោចចុងហើយងាប់ក៏ដូចករណីកង្វះមានភាពធ្ងន់ធ្ងរ។
- ស្រូវកូដជាតិមានដើមតឿ
- បន្ថយការបែកគុម្ព ចំនួនកួរ ចំនួនគ្រាប់ និង ទម្ងន់គ្រាប់។

# តួនាទីរបស់សារធាតុចិញ្ចឹម

- អាសូត (N)

- តម្រូវការអាសូត(N)

តម្រូវការអាសូត(N) នៃដំណាំស្រូវមានកំរិតខ្ពស់ចាប់ពីដំណាក់កាលបែកគុម្ព ដល់ចេញផ្កា និងធ្លាក់ចុះមកវិញនៅដំណាក់កាលទុំ ។

# តួនាទីរបស់សារធាតុចិញ្ចឹម

- ផូស្វ័រ(P)
- តួនាទីរបស់ផូស្វ័រ(P)
- ផូស្វ័រមានមុខងារយ៉ាងសំខាន់ក្នុងការផ្ទុកនិងផ្ទេរថាមពលក្នុងរុក្ខជាតិ ។
- ជំរុញការបែកគុម្ព
- ការអភិវឌ្ឍន៍ឬស
- ចេញផ្ការហ័សនិងទុំ និងជាពិសេសក្នុងដំណាកើកាលលូតលាស់ដំបូង។

- កង្វះផូស្វ័រ(P)
- រុក្ខជាតិតឿនិងមានពណ៌បៃតងក្រម៉ៅ
- មានស្លឹកឈរត្រង់ ហើយកាត់បន្ថយការបែកគុម្ព
- រុក្ខជាតិពន្យាពេលចេញផ្កា និងទុំ ហើយចំនួនគ្រាប់ស្កកមានច្រើន។

# តួនាទីរបស់សារធាតុចិញ្ចឹម

- ផូស្វ័រ(P)

- តម្រូវការផូស្វ័រ(P)

តម្រូវការផូស្វ័រ(P) នៃដំណាំស្រូវមានកំរិតខ្ពស់ចាប់ពីដំណាក់កាលបែកគុម្ព ដល់ចេញផ្កា និងធ្លាក់ចុះមកវិញនៅដំណាក់កាលទុំ ។

# រូបភាពកង្វះផូស្វរ








រុក្ខជាតិក្រិន តូច និងឈរត្រង់ បើប្រៀបធៀបជាមួយរុក្ខជាតិធម្មតា។

# រូបភាពកង្វះផូស្វរ




ការបែកគុម្ពមានការថយចុះនៅកន្លែងដែលខ្វះ P

# តួនាទីរបស់សារធាតុចិញ្ចឹម

- ប៉ូតាស្យូម(K)
- តួនាទីរបស់ប៉ូតាស្យូម(K)
- ដឹកនាំសារធាតុចិញ្ចឹមទៅអោយ កោសិកា។
- ជួយបង្កើនចំនួនកន្សោមផ្កាក្នុងមួយគួរ ភាគរយនៃគ្រាប់ស្រូវពេញនិងទម្ងន់១០០០គ្រាប់។
- វាជួយដល់ការលូតលាស់នៃឬស ការបែកគុម្ព និងដើមបែកផ្តល់ផល
- ជាពិសេសវាជួយបង្កើនគុណភាពគ្រាប់ ធ្វើអោយដំណាំឆាប់ចេញផ្កា និងទុំ ។
- កង្វះប៉ូតាស្យូម(K)
- ស្លឹកស្រូវមានពណ៌បៃតងក្រមៅ
- គែមស្លឹកមានពណ៌ត្នោតលាយលឿងខ្ចី ឬស្នាមអុចៗពណ៌ត្នោតក្រមៅលេចឡើងមុនគេនាំខាងចុងស្លឹកចាស់ៗ។

# តួនាទីរបស់សារធាតុចិញ្ចឹម

- ប៉ូតាស្យូម(K)

- តម្រូវការប៉ូតាស្យូម(K)

តម្រូវការប៉ូតាស្យូម(K) នៃដំណាំស្រូវមានកំរិតខ្ពស់ចាប់ពីដំណាក់កាលបែកគុម្ព ដល់ចេញផ្កា និងធ្លាក់ចុះមកវិញនៅដំណាក់កាលទុំ ។









# តួនាទីរបស់សារធាតុចិញ្ចឹម









# តួនាទីរបស់សារធាតុចិញ្ចឹម

- សង្កសី (Zn)
- តួនាទីរបស់ស័ង្កសី(Zn)

- ដំណើរការគីមីជីវៈក្នុងដំណាំស្រូវ។
- ប្រមូលផ្តុំនៅក្នុងឫស
- ផ្លាស់ទីឫសទៅផ្នែកលូតលាស់ផ្សេងៗ

• កង្វះសង្កសី (Zn)

- ចំនុចៗពណ៌ត្នោតដូចម្សៅនៅលើផ្ទៃស្លឹកផ្នែកខាងលើនៃរុក្ខជាតិក្រិន បន្ទាប់ពីស្ទូងបាន២ទៅ៣អាទិត្យ
- លូតលាស់មានលក្ខណៈមិនស្មើគ្នា
- រុក្ខជាតិតឿ

# តួនាទីរបស់សារធាតុចិញ្ចឹម

- ស្ពាន់ធ័រ (S)

- តួនាទីរបស់ស្ពាន់ធ័រ(S)
- សំយោគប្រូតេអ៊ីនមុខងាររបស់រុក្ខជាតិ និងទម្រង់របស់រុក្ខជាតិ។

- កង្វះស្ពាន់ធ័រ (S)
- រុក្ខជាតិមានពណ៌បៃតងស្លេក
- ស្លឹកខ្ចីៗមានពណ៌បៃតងស្រាល

# តួនាទីរបស់សារធាតុចិញ្ចឹម

- ម៉ាញេស្យូម (Mg)

- តួនាទីរបស់ម៉ាញេស្យូម(Mg)
- មានលក្ខណៈងាយស្រួលក្នុងការផ្លាស់ទី
- ធាតុផ្សំនៃក្លរភីល
- ចូលរួមក្នុងវិស្មីសំយោគ
- ប្តូរទឹកនៃ្ទងយ៉ាងលឿនពីស្លឹកចាស់ទៅស្លឹកថ្មី

- កង្វះម៉ាញេស្យូម (Mg)
- ការបាត់បង់ជាតិក្លរភីលនៅចន្លោះសរសៃស្លឹក ពណ៌លឿងទឹកក្រូចនៅលើស្លឹកចាស់ៗ

# ការប្រើប្រាស់ជីឲ្យបានត្រឹមត្រូវ

មានវិធីច្រើនយ៉ាងក្នុងការ ប្រើប្រាស់ជី។

- ការបាចដោយផ្ទាល់
- ការកប់ចូលទៅក្នុងដី
- ការប្រើជាមួយប្រព័ន្ធស្រោចស្រព
- ការប្រើជីគ្រាប់ធំ
- ការបាញ់ជីទឹក









# បទដ្ឋានប្រើប្រាស់ជី

| កម្រិតប្រើប្រាស់ជី (សម្រាប់ដីគ្រប់ប្រភេទ) | | | | |
|---|---|---|---|---|
| ប្រភេទជី | ទ្រាប់បាត (kg/ha) | បាចបំប៉ន (kg/ha) | | សរុប (kg/ha) |
| | | លើកទី១ | លើកទី២ | |
| DAP (18-46-0) | 50 | 0 | 0 | 50 |
| UREA (46-0-0) | 27 | 50 | 50 | 127 |
| KCl (0-0-60) | 10 | 20 | 20 | 50 |

# ពេលវេលានៃការបាចជី

## ពូជផ្ការំដួល

| ពេលវេលាសាប | បំប៉ន់លើកទី១ | បំប៉ន់លើកទី២ |
|---|---|---|
| 1-31 June | 30 DAT | 8-12 September |
| 1-15 July | 30 DAT | 13-17 September |

# ពេលវេលានៃការបាចជី

## ពូជរាំងជ័យ

| ពេលវេលាសាប | បំប៉នលើកទី១ | បំប៉នលើកទី២ |
|---|---|---|
| 1-31 June | 30 DAT | 1-5 October |
| 1-15 July | 30 DAT | 6-10 October |
| 16-30 July | 30 DAT | 11-15 October |

# សូមអរគុណ